ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់សាកលវិទ្យាល័យខេមរៈ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតរបស់លោក នូ ចាន់សុភី ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៤
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រ េ ច

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យខេមរៈ Khemarak University ហៅកាត់ជាភាសាខ្មែរ "ស.ខ." និងហៅកាត់ជាភាសាអង់គ្លេស "K.U."។

សាកលវិទ្យាល័យខេមរៈ មានទីតាំងស្ថិតនៅអាគារប្រវេះ មហាវិថីព្រះសីហនុ (២៧៤) កែងនឹងផ្លូវសម្ដេចសុធារស (៣) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

មាត្រា ២ : សាកលវិទ្យាល័យខេមរៈ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : សាកលវិទ្យាល័យខេមរៈ ធ្វើការបណ្ដុះបណ្ដាលថ្នាក់ :

- បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ
- បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ
- ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ
- បណ្ឌិតសិក្សាស្រាវជ្រាវរយៈពេលយ៉ាងតិច ៣ ឆ្នាំ ។

សាកលវិទ្យាល័យខេមរៈត្រូវរៀបចំកម្មវិធីសិក្សាលំអិតដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យខេមរៈ មាន ៧ មហាវិទ្យាល័យ :

១. មហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ
២. មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
៣. មហាវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និង ទំនាក់ទំនងអន្តរជាតិ
៤. មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និង ទេសចរណ៍
៥. មហាវិទ្យាល័យមនុស្សសាស្ត្រ សិល្បៈ និងភាសាវិទ្យា
៦. មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទ
៧. មហាវិទ្យាល័យវិទ្យាសាស្ត្របច្ចេកវិទ្យា និងព័ត៌មានវិទ្យា

និង មានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងស្រាវជ្រាវមួយ ។

ទៅអនាគត សាកលវិទ្យាល័យខេមរៈ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទបណ្ដុះបណ្ដាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៥ : សាកលវិទ្យាល័យខេមរៈ មានក្រុមប្រឹក្សាភិបាលមួយ សំរាប់ពិនិត្យសំរេច លើគោលនយោបាយ ផែនការអភិវឌ្ឍ និងក្រុមប្រឹក្សាបណ្ឌិតវិទ្យាសាស្ត្រមួយ សំរាប់អនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៦ : ក្នុងល័ក្ខខ័ណ្ឌទទួលនិស្សិតអោយចូលរៀន សាកលវិទ្យាល័យខេមរៈត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់អំពីការទទួលនិស្សិតអោយចូលរៀន នៅតាមគ្រឹះស្ថាន-ឧត្តមសិក្សា ។

មាត្រា ៧ : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យខេមរៈ មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន សាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អនូវការងារសិក្សា ការងារស្រាវជ្រាវ ការប្រលង និងការប្រគល់សញ្ញាប័ត្រ ។

- គោរព និងអនុវត្តតាម បទដ្ឋានរបស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា។
- ធានាអោយបាននូវសុវត្ថិភាព និងសណ្ដាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៨ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យខេមរៈ និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលបានសញ្ញាប័ត្រ តាមកំរិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្ដល់អោយដោយសាកលវិទ្យាល័យខេមរៈ ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បំពេញនិងអនុវត្តបាន តាមគោលការណ៍កំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យខេមរៈ មានភារកិច្ចអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
  "ដើម្បីជូនការ"
- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ -កាលប្បវត្តិ